# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0152**

## សម្ភាសន៍ជាមួយឈ្មោះ រ័ត្ន ស៊ីណាន ភេទស្រី អាយុ៥៨ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ “កងអង្គរ”

ស្រុកកំណើតភូមិព្រះនេត្រព្រះ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

សព្វថ្ងៃរស់នៅភូមិកណ្ដាល ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ហ៊ិន សុធានី

០០:៣៩:៤៤

២២ទំព័រ

ធានី : ថ្ងៃនឹង ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ។ ខ្ញុំឈ្មោះ ធានី ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយពួកខ្ញុំចុះមកនេះ គ្រាន់តែចង់សាកសួរមីង ពីប្រវត្តិរបស់មីង ដែលមីងបានឆ្លងកាត់កាលពីសម័យខ្មែរក្រហមយ៉ាងម៉េច ។ ហើយរឿងរ៉ាវអស់នេះ ពួកខ្ញុំសុំយកមកចងក្រងធ្វើជាសៀវភៅ ចុះទស្សនាវដ្ដី ឬឲ្យអ្នកស្រាវជ្រាវផ្សេងៗ បានរៀនបានសូត្រ សម្រាប់ឲ្យក្មេងក្រោយៗបានដឹង បានឮ ។ ចឹងជាដំបូងសុំថតជាសម្លេង ក៏ដូចជាថតជារូប បានទេមីង?

ស៊ីណាន : បានតើប៉ុនមិនដឹងនិយាយថាអី ។

ធានី : មីងមានឈ្មោះអីដែរ?

ស៊ីណាន : រ័ត្ន ស៊ីណាន ។

ធានី : ឆ្នាំនឹងមីងអាយុប៉ុន្មាន?

ស៊ីណាន : ឆ្នាំនេះ ៥៨ ។

ធានី : មីងមានស្រុកកំណើតនៅណាដែរ?

ស៊ីណាន : ព្រះនេត្រព្រះ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

ធានី : រាល់ថ្ងៃមីងរស់នៅណាវិញ?

ស៊ីណាន : មកនេះឯង ។

ធានី : នៅភូមិអីដែរ?

ស៊ីណាន : ភូមិកណ្ដាល ។

ធានី ៖ ឃុំអីដែរ?

ស៊ីណាន ៖ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ភូមិកណ្ដាល ។

ធានី ៖ ឪពុកមីងឈ្មោះអីគេ?

ស៊ីណាន ៖ ឪពុកខ្ញុំឈ្មោះ យិន ។

ធានី ៖ អីគេយិន?

ស៊ីណាន ៖ ស្ដីទេ ទូច យិន ។

ធានី ៖ ទូច យិន?

ស៊ីណាន ៖ ចា៎!

ធានី ៖ គាត់នៅរស់ទេ?

ស៊ីណាន ៖ ទេ! ស្លាប់ហើយ ។

ធានី ៖ ស្លាប់ពេលណា?

ស៊ីណាន ៖ ស្លាប់សម័យប៉ុលពតនេះ យួនចូលនេះឯង ។

ធានី ៖ ឆ្នាំប៉ុន្មានទេ?

ស៊ីណាន ៖ ទេ! បានប៉ុន្មាន៥-១៦ឆ្នាំទេដឹង យូរហើយ ។

ធានី ៖ រាប់ពីនេះទៅ១៥-១៦ឆ្នាំ?

ស៊ីណាន ៖ នោះហើយ ១៥ឆ្នាំទេដឹង ។

ធានី ៖ ចឹងឥឡូវ២០១១ ៩០ជាង?

ស៊ីណាន ៖ ៨៦ ៨៧ ៨៨ ៨៩ ហ៊ា!ដូចជា៩០គត់ ។

ធានី ៖ គាត់ស្លាប់ដោយសារអីដែរ?

ស៊ីណាន ៖ គាត់ជម្ងឺរោគាមនុស្សចាស់ ។

ធានី ៖ ចុះម្ដាយ?

ស៊ីណាន ៖ ម្ដាយឈ្មោះ កិន លឿន ។

ធានី ៖ គាត់នៅរស់ទេ?

ស៊ីណាន ៖ ស្លាប់ដែរ ។

ធានី ៖ ដោយសារអីដែរ?

ស៊ីណាន ៖ ស្លាប់ដោយជម្ងឺនឹងឯង ។

ធានី ៖ ឆ្នាំប៉ុន្មាន?

ស៊ីណាន ៖ ម៉ែខ្ញុំ២០០៥ ។

ធានី ៖ ឥឡូវៗនឹងដែរ?

ស៊ីណាន ៖ ចា៎!

ធានី ៖ មីងមានបងប្អូនប៉ុន្មាននាក់ដែរ?

ស៊ីណាន ៖ បងប្អូនខ្ញុំ៨នាក់ ។

ធានី ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ស៊ីណាន ៖ ស្រី៥ ប្រុស៣ ។

ធានី ៖ ស្រី៥ ប្រុស៣?

ស៊ីណាន ៖ ចា៎! ស្លាប់អស់២ ។

ធានី ៖ ស្លាប់ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ស៊ីណាន ៖ ស្លាប់ស្រី១ ប្រុស១ ។

ធានី ៖ ដោយសារអីដែរ?

ស៊ីណាន ៖ ជម្ងឺ ។

ធានី ៖ នៅឆ្នាំប៉ុន្មាន?

ស៊ីណាន ៖ មីងមួយស្លាប់សម័យបដិវត្ត ។

ធានី ៖ ស្រីនឹង?

ស៊ីណាន ៖ ស្រីចាស់ ។

ធានី ៖ បដិវត្តឆ្នាំប៉ុន្មានទៅ?

ស៊ីណាន ៖ បដិវត្តនេះដែរ ទើបយួនចូលដែរ សម័យនេះនោះឯង៧៩ ។

ធានី ៖ ម៉េចបានគាត់ស្លាប់ចឹង?

ស៊ីណាន ៖ ពោះធំ យើងកើតកូនសម័យនោះ ក៏យើងនោះឯង ។

ធានី ៖ ដល់ពេលប្រុសមួយនោះ?

ស៊ីណាន ៖ ប្រុសមួយនោះខូចសម័យនេះឯង ។

ធានី ៖ ឆ្នាំប៉ុន្មាន?

ស៊ីណាន ៖ ២០០៧ ។

ធានី ៖ មីងរៀបគ្រួសារនៅឆ្នាំប៉ុន្មាន?

ស៊ីណាន ៖ កាលខ្ញុំបាន៤២ គ្រួសារថ្មីខ្ញុំនឹង កាលគ្រួសារចាស់ខ្ញុំពី៧៣ ។

ធានី ៖ គាត់ឈ្មោះអីគេ?

ស៊ីណាន ៖ ណៃ ណាភ៉ា ។

ធានី ៖ តែគាត់ទៅណា?

ស៊ីណាន ៖ គាត់ស្លាប់រត់ទៅស្លាប់ ដុតគុកនៅខុត្តរមានជ័យ ។

ធានី ៖ ឆ្នាំប៉ុន្មានកាលនឹង?

ស៊ីណាន ៖ កាលនោះយួនចូលមកដែរ ជិតដល់ហើយនោះឯង ជិតចប់ហើយគេដុតខុត្តរមានជ័យ យើង ។

ធានី ៖ ៧០ជាង ឬ៨០ជាង?

ស៊ីណាន ៖ ៨០ មិនដល់៨០ទេដឹង អាពាឆ្នាំរស់ ពាឆ្នាំប៉ុន្មានខែដែលយើងចប់ ។

ធានី ៖ ពេលនឹងវៀតណាមអត់ទាន់ចូលដល់ទេ?

ស៊ីណាន ៖ អត់ទាន់ដល់ទេ នៅ៤-៥ថ្ងៃទៀត វៀតណាមចូល ក៏វាដុត ៧៩នេះហើយ ។

ធានី ៖ ឆ្នាំ៧៩នឹង?

ស៊ីណាន ៖ អឺ!

ធានី ៖ មានកូនប៉ុន្មាននាក់ដែរ?

ស៊ីណាន ៖ ខ្ញុំកូនមុន២នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ស៊ីណាន ៖ ប្រុសទាំង២ ។

ធានី ៖ ចុះរៀបគ្រួសារក្រោយ បានប៉ុន្មាននាក់?

ស៊ីណាន ៖ ប្រុស២នោះ ងាប់មួយហើយ សល់តែមួយទេ ។

ធានី ៖ ស្លាប់ដោយសារអី?

ស៊ីណាន ៖ ងាប់ ទៅថៃ ក៏ត្រីមុតដៃគេតាណុស ។

ធានី ៖ ស្លាប់ឆ្នាំប៉ុន្មាន?

ស៊ីណាន ៖ កូនខ្ញុំស្លាប់២០០៥ ។

ធានី ៖ ជំណាលយាយ?

ស៊ីណាន ៖ ចាំ! ហ៉ើ! ២០០៧ដឹង អាសម័យបោះឆ្នោត ។

ធានី ៖ បោះឆ្នោត២០០៨ ។

ស៊ីណាន ៖ ចាំ! នោះឯងសម័យបោះឆ្នោត ។

ធានី ៖ ចុះរៀបគ្រួសារក្រោយឆ្នាំប៉ុន្មាន?

ស៊ីណាន ៖ គ្រួសារក្រោយ ខ្ញុំ៨២ៗឡើង២០១១ៗ ៥៨ នេះនាង១៥-១៦ឆ្នាំ កូនខ្ញុំនេះ ១៦ឆ្នាំ ១៧ហើយ ។ ខ្ញុំបាន១៦ឆ្នាំ ។

ធានី ៖ ចឹង៩៥?

ស៊ីណាន ៖ ចាំ!

ធានី ៖ គ្រួសារថ្មីឈ្មោះអីគេ?

ស៊ីណាន ៖ ភឿ ប៊ូន ។

ធានី ៖ មានកូនប៉ុន្មាននាក់?

ស៊ីណាន ៖ កូនក្រោយនេះ ២នាក់ ។

ធានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ស៊ីណាន ៖ ស្រី២ ។

ធានី ៖ មីងមានបានរៀនបានសូត្រទេ?

ស៊ីណាន ៖ រៀនពីសង្គមមិញ ។

ធានី ៖ ថ្នាក់ទីប៉ុន្មានដែរ?

ស៊ីណាន ៖ ថ្នាក់ទី៧ ។

ធានី ៖ ថ្នាក់ទី៧ពីដើម?

ស៊ីណាន ៖ ចាំ!

ធានី ៖ អូ! ចេះច្រើន?

ស៊ីណាន ៖ មិនចេះទេ សព្វថ្ងៃក៏ភ្លេចអស់ ចាស់ហើយវាភ្លេចអស់ទៀតទៅហើយ ។

ធានី ៖ មីងរៀនថ្នាក់ទី៧នៅសាលាណាដែរ?

ស៊ីណាន ៖ សាលាណាទេ យូរណាស់ វាភ្លេចទៅ សាលាយើងនៅភូមិយើងនៅស្រុកយើងនេះឯង ។ អត់ទាន់បានប្រឡង ឡើងទាល់តែថ្នាក់នេះ បានទៅប្រឡងស្វាយ ។

ធានី ៖ ចុះប្រឡងចប់ថ្នាក់ទី៧នឹងម៉ង?

ស៊ីណាន ៖ ចាំ! អត់ទាន់បានប្រឡងទេ ថ្នាក់ទី៧ឈប់ៗ ខ្ញុំចូលដេរ មិនបានទៅប្រឡងទេ ។

ធានី ៖ ចុះមីងរៀនថ្នាក់ទី៧ រៀននៅសាលាយើង សាលាអីគេ សាលាព្រះនេត្រព្រះ ឬសាលាអី?

ស៊ីណាន ៖ សាលាព្រះនេត្រព្រះនេះឯង ស្រុកព្រះនេត្រព្រះ ឃុំព្រះនេត្រព្រះ ។

ធានី ៖ បន្ទាប់មកទៀត ម៉េចបានមីងឈប់រៀន?

ស៊ីណាន ៖ ឈប់ជីវភាពអត់ក្រទៅ ។

ធានី ៖ ឈប់រៀនធ្វើអីទៀតទៅ?

ស៊ីណាន ៖ ឈប់រៀនចូលដេរ ។

ធានី ៖ ដេរនៅណាវិញ?

ស៊ីណាន ៖ ដេរនៅព្រះនេត្រព្រះយើងនេះឯង ។

ធានី ៖ ដេរអីគេ?

ស៊ីណាន ៖ ដេរ ខោអាវ ។

ធានី ៖ នៅណាវិញ នៅព្រះនេត្រព្រះ នៅ?

ស៊ីណាន ៖ នៅក្នុងផ្សារ ផ្ទះគេបៀតវត្ត ។

ធានី ៖ ហើយម៉េចទៀតទៅ ដេរខោអាវហើយ ធ្វើអីទៀត?

ស៊ីណាន ៖ ដេរខោអាវ ខ្លះក៏ធ្វើស្រែ ។

ធានី ៖ មីងធ្វើស្រែដែរ?

ស៊ីណាន ៖ ធ្វើ ប្រូតស្រូវ ប្រូតអីទៅ ។

ធានី ៖ កាលពេលឈប់រៀននឹង ឈប់ឆ្នាំប៉ុន្មាន?

ស៊ីណាន ៖ ឈប់រៀនអាយុប៉ុន្មានទេ កាលនោះៗយូរណាស់ទៅហើយ ក៏ភ្លេចទៅហើយ ។ ខ្ញុំឈប់រៀនៗបានប៉ុន្មានឆ្នាំ ឈប់រៀនខ្ញុំចូលដេរបាន២ឆ្នាំៗខ្ញុំបានប្ដី ។

ធានី ៖ រៀបការនៅ៧៣?

ស៊ីណាន ៖ ចាំ! ការនៅ៧៣ ។

ធានី ៖ បន្ទាប់ម៉េចទៀតធ្វើអីទៀត?

ស៊ីណាន ៖ មិនមានអីប៉ុននោះក៏ធ្វើស្រែធ្វើភ្ជីទៅ ហូបទៅមិនដែលបានទៅណាទៅណែទេ នៅតែផ្ទះតែប៉ុននោះឯង ។

ធានី ៖ មីងកាលនៅ៧៣ចឹង មានគេដើរឃោសនាអីតាមភូមិយើងទេ?

ស៊ីណាន ៖ អត់មានផង ។

ធានី ៖ អត់មានដើរឃោសនាអីទេ?

ស៊ីណាន ៖ អត់ទេ ។

ធានី ៖ ចឹងគ្រួសារមីងអត់បានចូលរួម អត់ដែលឃើញគេឃោសនា?

ស៊ីណាន ៖ អត់មានទេ ។

ធានី ៖ ចឹងមីងនៅ៧៣ មីងនៅភូមិឃុំណាទៅ?

ស៊ីណាន ៖ នៅនេះឯង នៅស្រុកនេះ ។

ធានី ៖ ហើយបន្ទាប់មកទៀតក្រោពីឆ្នាំ៧៣ ៧៤ ៧៥ ធ្វើអីគេទៅ?

ស៊ីណាន ៖ ៧៤ ៧៥ ធ្វើតែស្រែ ដេរ ។

ធានី ៖ ចុះ៧៦?

ស៊ីណាន ៖ ៧៦ នៅតែដេរដដែល អត់មានធ្វើអីទេ តែដេរប៉ុននោះឯង ។

ធានី ៖ ចេះមីង រៀបការនៅឆ្នាំ៧៣ ហើយបន្ទាប់មកទៀតមីងនៅដេរធម្មតាដូចរាល់ដង?

ស៊ីណាន ៖ ដេរធម្មតា ។

ធានី ៖ ចឹងកាលពេលនឹង មីងដែលធ្លាប់ឃើញប្រជាជនថ្មីជម្លៀសមកទេ?

ស៊ីណាន ៖ ទេ! កាលនោះឃើញតើ ។

ធានី ៖ ឆ្នាំប៉ុន្មាន?

ស៊ីណាន ៖ ជម្លៀសមក៧៩នេះឯង ។

ធានី ៖ ៧៩ ឬ៧៥?

ស៊ីណាន ៖ អឺ! សម័យជម្លៀសយើង ៧៩ ៧៥ដឹង អាសម័យយួនចូល សម័យអាពតចូលមក ។

ធានី ៖ សម័យអាពត ឬសម័យយួន?

ស៊ីណាន ៖ សម័យអាពត១ នៅប្រជាជនសម័យជម្លៀសមក ។

ធានី ៖ ចឹងសម័យអាពត នៅឆ្នាំ៧០ប៉ុន្មាន?

ស៊ីណាន ៖ សម័យអាពតយើងនឹង ៧៥ សម័យអាពត ។

ធានី ៖ ៧៥ មីងបានឃើញគេជម្លៀសប្រជាជនថ្មី មកស្រុកយើង?

ស៊ីណាន ៖ ជម្លៀស មិនបានឃើញទេ ខ្ញុំស្រាប់តែឃើញគេមកនៅនោះម្តង ខ្ញុំទៅនៅខត្តរមានជ័យ ។
ស្រាប់តែមក ឃើញបងប្អូនប្រជាជនយើង ។

ធានី ៖ ចឹងមីងនៅខត្តរមានជ័យនៅឆ្នាំប៉ុន្មាន បើមីងថា៧៣មីង?

ស៊ីណាន ៖ ខ្ញុំការរួច ។

ធានី ៖ ការហើយ ៧៣?

ស៊ីណាន ៖ ចា៎! ។

ធានី ៖ ការហើយទៅនៅខត្តរមានជ័យ?

ស៊ីណាន ៖ នោះហើយ ។ ខ្ញុំការរួច ខ្ញុំនៅឧត្ដរមានជ័យ ។

ធានី ៖ ឧត្ដរមានជ័យនៅម្ដុំណា?

ស៊ីណាន ៖ នោះ នៅសំរោងយើងនេះណា បៀតស្នាច់ ។

ធានី ៖ ចឹងមីងទៅនៅនឹង រកស៊ី?

ស៊ីណាន ៖ រកស៊ី ។

ធានី ៖ ធ្វើអីគេ រកស៊ី?

ស៊ីណាន ៖ ដេរ លក់ខោអាវ ដេរចេះហើយ លក់ក្រណាត់ លក់អីវ៉ាន់ចាប់ហួយតិចតួចទៅ ខ្ញុំនៅបាន ប៉ុន្មានខែនេះណា ។

ធានី ៖ នៅបានប៉ុន្មានខែ កាលនឹង?

ស៊ីណាន ៖ នៅបាន៣ខែនោះឯង ខ្ញុំមកវិញ ។

ធានី ៖ ម៉េចចឹង?

ស៊ីណាន ៖ ម៉ែឪខ្ញុំស្នើមកវិញ មកនៅជុំកូនជុំចៅវិញ ។

ធានី ៖ ម្ដាយហៅមកវិញ?

ស៊ីណាន ៖ ចាំ!

ធានី ៖ នៅជុំបងប្អូន?

ស៊ីណាន ៖ នៅជុំបងប្អូនវិញ ម៉ែឪវិញ ។

ធានី ៖ ចឹងត្រឡប់មកភូមិយើងវិញ?

ស៊ីណាន ៖ មកភូមិយើងវិញ ។

ធានី ៖ មីងថាមកភូមិយើងវិញ ស្រាប់ឃើញអ្នកថ្មីមកដល់ហើយ?

ស៊ីណាន ៖ ទេ! នោះហើយ ខ្ញុំមកវិញឃើញបងប្អូនថ្មី ។

ធានី ៖ ចុះមីងថា?

ស៊ីណាន ៖ ពួកខ្ញុំនេះនៅឧត្ដរមានជ័យ ក៏គេជម្លៀសទៅដែរតើ ។

ធានី ៖ ជម្លៀសទៅណា?

ស៊ីណាន ៖ ជម្លៀសទៅភូមិគេនោះឯង ភូមិគេហៅភូមិឈូកៗ ។

ធានី ៖ ភូមិឈូកនៅណា?

ស៊ីណាន ៖ ភូមិឈូកៗ នៅបានម៉ាខែ ក៏ម៉ែឪស្នើយកមកវិញ ។

ធានី ៖ ជម្លៀសភូមិឈូក នៅឧត្ដរមានជ័យដែរ?

ស៊ីណាន : ចាំ! ខត្តរមានជ័យ គេហៅភូមិឈូកៗ ។

ធានី : ម៉េចបានគេជម្លៀសមីងទៅចឹង?

ស៊ីណាន : ចុះគេ អ្នកភូមិអ្នកស្រុកគេជម្លៀសតែចឹងឯង គេឲ្យចេញៗទៅនឹងគេ ។

ធានី : តែម្ដាយមីងស្នើមកវិញ?

ស៊ីណាន : នោះឯង ស្នើមក ។

ធានី : ចឹងមីងនៅខត្តរមានជ័យនៅបានយូរ ឬឆាប់ ព្រោះមីងថា៧៣មីងការ ហើយទៅបាន៣ខែ មកវិញស្រាប់តែគេជម្លៀស?

ស៊ីណាន : មកវិញ ។

ធានី : មកវិញ ដល់មកដល់ភូមិយើងនេះវិញ?

ស៊ីណាន : ទេ! ដល់ភូមិយើងឃើញប្រជាជនថ្មីនៅៗមិនទាន់ចេញទេ ប្រជាជនថ្មីទាល់តែខ្ញុំកើតកូនបាន មួយទៀត ។

ធានី : ចុះអ៊ំមិញ អ៊ំថានៅឆ្នាំ៧៥ប្រជាជនថ្មីជម្លៀសមក?

ស៊ីណាន : មកដល់ឃើញប្រជាជនថ្មីនៅនោះ ទាល់តែខ្ញុំបានកូនមួយទៀត បានស្រុកចប់សង្គ្រាមស្រុក យួនចូល ។

ធានី : ចឹងកាលពេលអ៊ំមក ដល់ឃើញប្រជាជនថ្មីចឹង អ៊ំទៅនៅកន្លែងណា?

ស៊ីណាន : ខ្ញុំនៅកន្លែងផ្ទះម្ដាយខ្ញុំ ។

ធានី : នៅណាវិញ នៅភូមិយើង?

ស៊ីណាន : នៅភូមិយើង គេជម្លៀសទៅម៉្តុំចំការយើងក្រោយសាលារៀន ។

ធានី : ចឹងអ៊ំនៅនឹងធ្វើអីគេទៅ?

ស៊ីណាន : នៅធ្វើគេឲ្យធ្វើការងារគាត់នោះឯង ។

ធានី : ការងារអីគេ?

ស៊ីណាន : មុនដំបូងគេឲ្យ ខ្ញុំសរសៃខ្ទីៗ គេឲ្យកិនស្រូវ ។

ធានី : ចឹងដោយសារអ៊ំជម្លៀសពីមកខត្តរមានជ័យមកនឹងសម្រាលកូន?

ស៊ីណាន : ចាំ!

ធានី : សម្រាលបានកូនស្រី កូនប្រុស?

ស៊ីណាន : កូនប្រុស១ ។

ធានី : ហើយមកដល់ផ្ទះម្ដាយ ក៏?

ស៊ីណាន ៖ ចា៎! ផ្ទះម្ដាយ ក៏ ។

ធានី ៖ បានប៉ុន្មានខែ?

ស៊ីណាន ៖ បាន៣ខែ បានគេឲ្យធ្វើការទៅ ចូលធ្វើការកិនស្រូវឲ្យគេ ដែលយើងសរសៃខ្វីធ្វើអីមិនកើត ក៏ ។

ធានី ៖ កិនស្រូវនៅណាវិញ?

ស៊ីណាន ៖ នៅភូមិនេះឯង ។

ធានី ៖ ស្រូវនឹង រោងស្រូវជាមួយម្ដាយមីងដែរ?

ស៊ីណាន ៖ អត់ទេ ។

ធានី ៖ ម្ដាយមីងធ្វើការអីគេ?

ស៊ីណាន ៖ ម៉ែខ្ញុំគាត់ធ្វើការផ្សេងនៅរោងបាយ ។

ធានី ៖ គាត់នៅរោងបាយ?

ស៊ីណាន ៖ ចា៎!

ធានី ៖ គាត់ជាអីគេ?

ស៊ីណាន ៖ ជីវភាព ។

ធានី ៖ ងារគាត់ជាអីគេ នៅរោងបាយនឹង?

ស៊ីណាន ៖ ងារគាត់ជាអ្នកដាំបាយជីវភាព ដាំបាយ ដាំបបរ ។

ធានី ៖ ដាំម្នាក់ឯងទេ?

ស៊ីណាន ៖ ទេ! គ្នាច្រើនណាស់ ។

ធានី ៖ តែអ្នកណា ធ្វើជាប្រធានគាត់?

ស៊ីណាន ៖ មិនដឹងទេ ។

ធានី ៖ គាត់ប្រធាន ឬក៏?

ស៊ីណាន ៖ នោះហើយ ទេគាត់មិនមែនប្រធានទេ គាត់កូនចៅ ។

ធានី ៖ តែគាត់អ្នកដាំបាយ?

ស៊ីណាន ៖ អ្នកដាំបាយ ។

ធានី ៖ អ្នកដាំបាយជីវភាព?

ស៊ីណាន ៖ ជីវភាព ។

ធានី ៖ ដាំបាយនៅ អានឹងគេហៅសហករណ៍អីគេ មីងដឹង?

ស៊ីណាន ៖ សហករណ៍ប៉ុន្មានទេ កាលនោះខ្ញុំមកថ្មី មិនសូវដឹងផងៗ មកពីខត្តរមានជ័យ ក៏មិនដឹងជាសហករណ៍ប៉ុន្មាន សហករណ៍៤-៥ពីណាទេពីដើមមិញ មិនដែលបានដឹងៗ

ធានី ៖ ចឹងគ្រួសារមីងទៅណាវិញ បើមីងមកកិនស្រូវ?

ស៊ីណាន ៖ គ្រួសារខ្ញុំ កាលនោះគាត់ស្លាប់ហើយតើ គាត់ស្លាប់គេដុតគុកខត្តរមានជ័យ ។ ខ្ញុំនៅតែឯងៗ

ធានី ៖ ចឹងតាំងពីឆ្នាំ៧០ជាង ដែលគេដុត?

ស៊ីណាន ៖ នោះហើយ ។

ធានី ៖ ៧០ប៉ុន្មាន មីងចាំទេកាលនឹង?

ស៊ីណាន ៖ ដឹង៧០ប៉ុន្មានទេ មើលកូនខ្ញុំមក កូនខ្ញុំឆ្នាំថោះ ខ្ញុំចេញមក ។ ខ្ញុំចេញពីខត្តរមានជ័យមកខ្ញុំកើតកូនរំដួលនេះ កូនខ្ញុំឆ្នាំថោះ ។

ធានី ៖ ចឹងកូនក្រោយនឹង មីងថាមានកូន២?

ស៊ីណាន ៖ កូនក្រោយ កូនប្ដីក្រោយស្រីទាំង២ ។

ធានី ៖ ចឹងមីងរកនឹកមើល ៧៣មីងរៀបគ្រួសារទៅនៅខត្តរមានជ័យ នៅបាន៣ខែគេជម្លៀសឲ្យមកវិញ?

ស៊ីណាន ៖ មិនមែន៣-៤-៥ខែទេ ដឹងប៉ុន្មានទេ ។

ធានី ៖ កាលនឹងមានកូនទី១នៅ?

ស៊ីណាន ៖ កាលនឹងកូនទី១ ពោះធំកូនទី១នោះឯង ។

ធានី ៖ បានកូនទី១ហើយ បានគេជម្លៀសឲ្យមីងទៅនៅភូមិឈូកនឹង?

ស៊ីណាន ៖ នោះហើយ ។

ធានី ៖ កូនទី១បានប៉ុន្មានឆ្នាំ បានគេចាប់ផ្ដើមជម្លៀស កូនបន្ទាប់ទៀត?

ស៊ីណាន ៖ កូនទី១ខ្ញុំនៅពោះណា ។

ធានី ៖ ចុះមីងថាមានកូន២នោះ?

ស៊ីណាន ៖ កូនខ្ញុំ២ កូនមួយកើតនេះឯង ។

ធានី ៖ កើតនៅភូមិយើងនេះ?

ស៊ីណាន ៖ ចាំ! អាប្អូនកើតនៅភូមិយើង អាបងខ្ញុំមកពីនោះវិញ ខ្ញុំមកកើតតាមផ្លូវ មកកើតនៅរំដួល ។

ធានី ៖ អត់ទាន់សួរយល់ ព្រោះមីងប្រាប់ខ្ញុំថា ពេលមីងរៀបការនៅឆ្នាំ៧៣ក្លាម មីងទៅនៅខត្តរមានជ័យ?

ស៊ីណាន ៖ ចាំ!

ធានី ៖ នៅខត្តរមានជ័យមីងទៅរកស៊ី?

ស៊ីណាន ៖ ចាំ!

ធានី ៖ ទៅរកស៊ីនឹង មីងមានកូនទី១នៅ?

ស៊ីណាន ៖ មិនទាន់មានទេ នៅក្នុងពោះ ។

ធានី ៖ ដល់ពេលមីងត្រឡប់មកវិញបានកើតកូននឹងមក?

ស៊ីណាន ៖ ខ្ញុំជម្លៀសមកវិញ កើតកូនឆ្នាំថោះ កូនខ្ញុំ៣៧ឆ្នាំ ។

ធានី ៖ ចង់និយាយថាកូននឹងកូនបង?

ស៊ីណាន ៖ កូនបង ។

ធានី ៖ ពេលមីងដើរមកវិញនឹង គ្រួសារមីងចាប់ដុតនឹង?

ស៊ីណាន ៖ ទេ! អត់បានមកទេ ដុតនៅនោះ ។

ធានី ៖ អត់បានមកវិញ ដុតនោះ ចឹងមីងបានកូនទី២មកពីណា?

ស៊ីណាន ៖ កូនទី២ មានកូនទី២រួច បានគ្រួសារខ្ញុំចេញ ។

ធានី ៖ ខ្ញុំអត់ទាន់យល់កន្លែងនឹង សុំសួរមីងមានកូនទី២គ្រួសារមីងចេញម៉េច?

ស៊ីណាន ៖ គ្រួសារខ្ញុំចេញ ព្រោះគ្រួសារខ្ញុំរត់កាលឆ្នាំម្យាញ់ ។

ធានី ៖ រត់?

ស៊ីណាន ៖ ចាំ! គ្រួសារខ្ញុំរត់កាលឆ្នាំម្យាញ់ ។ ខ្ញុំមានកូនអាប្អូន ខ្ញុំកើតកូនអាប្អូននេះរួច ។

ធានី ៖ ចឹងបានន័យថាគ្រួសារមីងនៅភូមិនេះ រត់ទៅនៅខត្តរមានជ័យ?

ស៊ីណាន ៖ ចាំ! រត់គេចខ្លួនទៅ គេចាប់បាន ។

ធានី ៖ មុនដំបូងស្មានតែគាត់អត់បានមកជាមួយមីងទេ?

ស៊ីណាន ៖ ទេ! មកៗជុំគ្នា ធ្វើការងាររត់គេទៅចល័ត ខាងនេះដើរចល័តដើរអី ។ ដល់ពេលនេះទៅ គេបបួលរត់ទៅ ក៏ទៅនឹងទេ ។

ធានី ៖ ឆ្នាំម្យាញ់នឹង គេចាប់បានស្លាប់?

ស៊ីណាន ៖ កាលឆ្នាំម្យាញ់នេះឯងគាត់រត់ទៅ ។

ធានី ៖ រត់ហើយគេចាប់បាន ក៏សម្លាប់ដែរ?

ស៊ីណាន ៖ ចាំ!

ធានី ៖ ពេលដែលមីងចេញមកធ្វើស្រូវអង្ករនឹង ធ្វើតែអង្ករនឹងតែម៉ាមុខនឹង?

ស៊ីណាន ៖ កិនស្រូវ ។

ធានី ៖ កិនស្រូវម៉ាមុខ?

ស៊ីណាន ៖ កិនស្រូវ ថ្ងៃណាគេមិនមានស្រូវកិន គេឲ្យយើងទៅដរស្មៅ គេដាំស្ពៃ ដកស្មៅស្ពៃ ។

ធានី ៖ កិនស្រូវនឹងគេធ្វើម៉េចខ្លះ?

ស៊ីណាន ៖ គេដាក់ទិសដៅមួយឲ្យកិន ក្នុងត្បាល់មួយតែ២បាវ ។

ធានី ៖ រួចទេ?

ស៊ីណាន ៖ រួចតើ គ្នា៤-៥នាក់ត្បាល់មួយក៏២-៣នាក់ទៅ អ្នកកិនក៏កិន អ្នករែង អ្នកអុំទៅណា ។

ធានី ៖ ហើយមីងស្គាល់ប្រធាន អ្នកកិនស្រូវនោះទេ?

ស៊ីណាន ៖ អឺ! ឲ្យនៅក្នុងសម័យនោះ អ្នកណាប្រធានទេភ្លេចអស់ ។ ឲ្យបានខ្ញុំកិនស្រូវ មាននេះណា សម័យនោះពួកកំពង់ឆ្នាំង មិននេះទេណា ។

ធានី ៖ តែមីងស្គាល់ឈ្មោះគាត់ទេ?

ស៊ីណាន ៖ ឈ្មោះ ស្គាល់ នាង រ៉ែម ប្រធានអាពត នាងរ៉ែម គេនៅប្រធានស្រុកនេះ ។

ធានី ៖ រ៉ែមប្រធានធំ?

ស៊ីណាន ៖ នោះហើយ យ៉ែម១, យឺង១ ប្រធានធំ ។

ធានី ៖ ស្រីប្រុស យ៉ែម?

ស៊ីណាន ៖ យ៉ែមនោះ ស្រី ។

ធានី ៖ ចុះយឺង?

ស៊ីណាន ៖ យឺងនោះប្រុស ។

ធានី ៖ ហើយរ៉ែម?

ស៊ីណាន ៖ រ៉ែមនោះឯង ស្រី ។

ធានី ៖ រ៉ែមនឹងប្រធានរបស់មីង?

ស៊ីណាន ៖ ទេ! ប្រធានទូទៅទាំងអស់នឹង មិនមានប្រធានតែខ្ញុំទេ គេនៅកាន់ក្តាប់ ។

ធានី ៖ នៅសហករណ៍យើង?

ស៊ីណាន ៖ នៅសហករណ៍យើង នៅក្នុងឃុំង ដូចថាមានឃុំងមួយគេនៅក្តាប់ ។

ធានី ៖ ឃុំងអីគេ?

ស៊ីណាន ៖ ឃ្លាំងអង្ករ ឃ្លាំងស្រូវ ។

ធានី ៖ ខ្ញុំចង់សួរថា ឃ្លាំងគេ ឃ្លាំងសម្រាប់សហករណ៍ ស្រុក ឃុំ តំបន់?

ស៊ីណាន ៖ ទេ! សហករណ៍ៗនោះដូចថាគេមានអំបិល មានស្ពឺៗនៅក្នុងនោះណា ។

ធានី ៖ អត់ដឹងសហករណ៍នឹងឈ្មោះអីទេ?

ស៊ីណាន ៖ ទេ! មិនដឹងទេ ។

ធានី ៖ ហើយចឹងមីង បន្ទាប់មកទៀត?

ស៊ីណាន ៖ កាលនោះសម័យនិរតីទៅហើយ គេនៅកាន់កាប់ ។

ធានី ៖ ឈ្មោះ យ៉ែម យើងនឹង?

ស៊ីណាន ៖ នោះឯង ។

ធានី ៖ សម័យនិរតី គាត់នៅកំពង់ឆ្នាំង?

ស៊ីណាន ៖ សម័យនិរតីនេះ ក៏គេជម្លៀសពីកំពង់ឆ្នាំងមក ។

ធានី ៖ ចុះអ្នកចាស់ មកពីណាវិញ?

ស៊ីណាន ៖ ទេ! អ្នកចាស់ខ្ញុំមកមិនទាន់ទេ ទាន់តែពួកនិរតី ។

ធានី ៖ ចឹងអ៊ំអត់ទាន់ពួកនិរតី?

ស៊ីណាន ៖ ខ្ញុំទាន់ពួកនិរតី ពួថានិរតីៗ ។

ធានី ៖ និយាយទៅ សម័យនឹង គេអត់ឲ្យដើរហើរអីដូចចុះឡើងបាន ម៉េចក៏អ៊ំអាចដូរពីខត្តរមានជ័យមកនៅនេះបាន?

ស៊ីណាន ៖ ម៉ែក្មេកខ្ញុំ គាត់ស្នើសុំពីឃុំព្រះនេត្រព្រះទៅយកមក ។

ធានី ៖ ប៉ុន្តែធ្វើម៉េចបានយកបាន?

ស៊ីណាន ៖ យកបាន ទៅដល់ ។

ធានី ៖ ម៉ែក្មេកអ៊ំនឹងជាអ្នកណាគេ?

ស៊ីណាន ៖ ម៉ែក្មេកខ្ញុំ អ្នកស្រុកប្រជាជនធម្មតា ។

ធានី ៖ ម៉េចបានគាត់អាចស្នើបាន ព្រោះធម្មតាគេស្នើចឹង គេមិនឲ្យស្នើ បើយើងអត់មានមុខងារ ។

ស៊ីណាន ៖ ទេ! កាលនោះស្នើបានមក ក៏ដល់ខ្ញុំឈ្មោះធំទៅ គេឲ្យក្របីម៉ានឹម រទេះមួយយកមក បរដឹកមក ។

ធានី ៖ ម៉ែក្មេងអ៊ំនឹងធ្វើអីគេ?

ស៊ីណាន ៖ ម៉ែក្មេកខ្ញុំអ្នកស្រែ អ្នកចំការយើងធម្មតាទេ គ្មានធ្វើអីទេ ។

ធានី ៖ គាត់ឈ្មោះអីគេ ម៉ែក្មេក?

ស៊ីណាន ៖ ម៉ែក្មេកខ្ញុំឈ្មោះ យ៉ាន ។

ធានី ៖ ឈ្មោះយ៉ាន គាត់នៅគណៈឃុំណា ឃុំនឹង?

ស៊ីណាន ៖ ស្លាប់ហើយ គាត់នៅស្រុកនេះឯង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះយើងនេះ ។

ធានី ៖ ចឹងម៉េចក៏កូនគាត់ចាំបាច់រត់ទៅនៅឧត្តរមានជ័យវិញ?

ស៊ីណាន ៖ កូនខ្ញុំមិនរត់អី ប្ដីប្រពន្ធខ្ញុំនោះឯង ទៅរកស៊ីនោះ ។

ធានី ៖ មិនមែនទេ ចង់និយាយថាធម្មតា ម៉ែក្មេករបស់អ៊ំចឹង ជិះឡាននឹង គាត់បានហៅគេនាំចេញ
មកវិញ ចាំបាញ់គ្រួសាររបស់អ៊ំរត់ទៅវិញធ្វើអី?

ស៊ីណាន ៖ មកវិញហើយ ទៅនៅភ្នូរនាម កាលនោះគេសម័យគេចាប់ គេសម្លាប់នោះ ឲ្យតែអ្នកណា
ធ្វើទាហានបេះគេចាប់ធ្វើបាន គេយកទៅសម្លាប់ ។

ធានី ៖ ចឹងគ្រួសារមីងធ្វើទាហានអីគេ?

ស៊ីណាន ៖ គ្រួសារខ្ញុំមានធ្វើទាហានអីគេ ។

ធានី ៖ ចុះម៉េចក៏?

ស៊ីណាន ៖ ទេ! ផ្អើលៗជុំគ្នាទៅ នៅម៉ាកងជុំគ្នាធ្វើស្រែ ភ្នូរស្រែ ឃើញគេផ្អើលក៏រត់ទៅនឹងគេ ។

ធានី ៖ រត់តាមគេទៅ?

ស៊ីណាន ៖ ចា៎! រត់តាមគេ ។

ធានី ៖ កាលនឹងម៉ែក្មេកអ៊ំ អត់ទាន់រត់ទៅទេ?

ស៊ីណាន ៖ ទេ! ម៉ែក្មេកខ្ញុំនៅនេះឯង នៅស្រុកព្រះនេត្រព្រះតើ ឪបង្កើត ម៉ែបង្កើតខ្ញុំក៏នៅនេះ ទៅ
តែខ្ញុំ២នាក់ប្ដីប្រពន្ធទេ ទៅនៅនោះ ។

ធានី ៖ ចង់និយាយថា ពេលដែល៧៣ អ៊ំការហើយអ៊ំទៅនៅឧត្តរមានន័យ អ៊ំត្រឡប់មកវិញ
ម៉ែក្មេកអ៊ំហៅមកវិញ?

ស៊ីណាន ៖ ចា៎! នោះហើយ ។

ធានី ៖ ហៅមកវិញហើយ ចាំបាច់ត្រឡប់ទៅវិញ បើម៉ែក្មេកអ៊ំខំហៅធានាឲ្យមកនៅនេះហើយ?

ស៊ីណាន ៖ មិនមានត្រឡប់ទៅវិញទេ ។

ធានី ៖ គ្រួសារអ៊ំរត់នោះ?

ស៊ីណាន ៖ គ្រួសារខ្ញុំរត់ ដ្បើលគេចាប់ សម័យគេចាប់សម្លាប់ គេរកពួកបញ្ញវ័ន្ត អ្នកមានអ្នកចេះ អ្នកដឹងដូចថានៅជុំគ្នា ។ ប្ដីខ្ញុំក៏រត់ទៅតាមគេទៅ ច្រើនណាស់នាង រត់ទៅជាង២០-៣០នាក់ ។ ប៉ុនរស់បានតែ២នាក់មកវិញទេ ។

ធានី ៖ ហេតុអី?

ស៊ីណាន ៖ គេស្រែកទៅ ពួកនោះចុះក្នុងទឹក ត្រាំទឹកក្នុងត្រពាំង ទៅប្ដីខ្ញុំគេហៅថាឡើងមកៗ គេមិនបានធ្វើអីទេ ក៏ឡើងមកម៉ាចំនួនឲ្យគេចាប់ ម៉ាចំនួន២នាក់នោះគេនៅសំងំក្នុងទឹកនោះ គេអត់ក្រោកៗ គេអត់ឡើងមកឲ្យគេចាប់ ដល់ហើយម៉ាចំនួននោះ គេចាប់បញ្ជូនពួកនេះអស់មកបានម៉ាចំនួននេះគេឡើងមក បានរស់ដើរទៅប្រទេសក្រៅនោះ ។

ធានី ៖ ហើយគេប្រាប់មីងទៅ?

ស៊ីណាន ៖ នោះឯង ។

ធានី ៖ ម៉េចបានមីងដឹង?

ស៊ីណាន ៖ ដឹងតាមគេអ្នកនៅនេះឯង ថាពួកយើង ។

ធានី ៖ ឈ្មោះអីគេដែលគាត់ប្រាប់គ្នាយើង?

ស៊ីណាន ៖ ឈ្មោះតាសួង១ គាត់ស្លាប់ហើយ ។

ធានី ៖ តាសួង?

ស៊ីណាន ៖ ចាំ! នេះជុំគ្នានឹងឯង ។

ធានី ៖ តាសួង គាត់នៅភូមិយើង?

ស៊ីណាន ៖ នៅជុំភូមិយើង ប៉ុនគាត់ស្លាប់ហើយ នៅនោះគាត់រស់បាន ។

ធានី ៖ ចឹងមីងនៅកិនស្រូវរហូតដល់បែកទៅ?

ស៊ីណាន ៖ ចាំ!

ធានី ៖ ចុះការហូបចុកអីម៉េចដែរ?

ស៊ីណាន ៖ មានអីទៅធម្មតា នៅស៊ីដំឡូង ។

ធានី ៖ ហូបបាយហូបអី? ០

ស៊ីណាន ៖ អូ! គ្មានបាយទេ តែបបរតែ១វែកប៉ុនោះ ដែលមានអីបានហូបគ្រប់គ្រាន់ ។

ធានី ៖ ចុះមីងនៅកន្លែងរោងអង្ករ?

ស៊ីណាន ៖ រោងអង្ករដែលហ៊ានលួចគេ រក្សាសុខឲ្យតែបានរស់ ។

ធានី ៖ ចុះអង្ករអស់នឹង មីងដឹងថាយកទៅណា?

ស៊ីណាន ៖ កិនចែកឲ្យប្រជាជន ។

ធានី ៖ តែម៉េចបានមីងហូបបបរវិញ បើកិនចែក?

ស៊ីណាន ៖ ចុះបើយើងដែលទៅបានចែកបាយ ។

ធានី ៖ ហេតុអីទៅ?

ស៊ីណាន ៖ កាលនោះម្នាក់ម៉ារបបម៉ាត្រួសារ២កំប៉ុង១ ។

ធានី ៖ គេចែកឲ្យដែរ ម្នាក់២កំប៉ុង?

ស៊ីណាន ៖ គេចែកឲ្យតើ ប៉ុនយើងតែបបរមានបាននេះណា ដែលមានបានបាយហូបទេ ។

ធានី ៖ ចឹងមីងដើរបេះនេះបេះនោះបានដែរ?

ស៊ីណាន ៖ បេះអាបន្លែយើងដែលដាំផ្ទះយើង ។

ធានី ៖ បេះបានដែរ?

ស៊ីណាន ៖ ចា៎! អាដំឡូងមី ដំឡូងអីយើងនៅផ្ទះក៏ឈូស ។

ធានី ៖ ចុះមីងមានចិញ្ចឹមសត្វចិញ្ចឹមអី?

ស៊ីណាន ៖ គ្មានអ្នកណាឲ្យចិញ្ចឹម១ទេ តែរបស់យើងមាន គេយកទៅអស់ ។

ធានី ៖ អ្នកណាគេមកយក?

ស៊ីណាន ៖ ពួករបស់អង្គការ ។

ធានី ៖ ចុះឈ្មោះ យ៉ែម, យឹមអីនឹង?

ស៊ីណាន ៖ នោះឯង ពួកនាងយ៉ែម នាងរ៉ាអីណាទេ សម័យនោះ ។

ធានី ៖ ចុះមីងស្គាល់អ្នកផ្សេងទៀតក្រៅពីពួកគាត់?

ស៊ីណាន ៖ ទេ មិនស្គាល់ទេ មិនដែលបានទៅណា នៅតែផ្ទះក៏ ប្ដីខ្ញុំមិនដែលបានចេញទៅចល័តទៅអីណា ។

ធានី ៖ ស្គាល់យាយចែម?

ស៊ីណាន ៖ យាយចែម មិនដែលស្គាល់ទេ ។

ធានី ៖ អត់ដែលឮ?

ស៊ីណាន ៖ ហ្នឹងហើយ ។ ទេ! យាយចែម១ដូចនៅនឹងឃុំនេះខ្ញុំដែរ ប្ដីខ្ញុំបានស្គាល់ច្បាស់ ខ្ញុំមិនសូវ ។

ធានី ៖ គាត់អ្នកនៅនឹងដែរ?

ស៊ីណាន ៖ ប្ដីខ្ញុំអ្នកនៅផ្ទាល់ ខ្ញុំអ្នកដំណើរ ប្ដីខ្ញុំអ្នកខាងចល័តខាងអីនេះគឺគាត់ ។

ធានី ៖ គាត់ចល័ត គាត់ធ្វើការងាររលើកទំនប់ដែរ?

ស៊ីណាន ៖ នោះហើយប្តីខ្ញុំ បើខ្ញុំមិនដែលបានធ្វើអីទេ ។

ធានី ៖ ចឹងគ្រួសារមីងនឹង គាត់លើទំនប់គ្រប់កន្លែង?

ស៊ីណាន ៖ គ្រួសារខ្ញុំធ្លាប់ទៅនៅរនាម គេឲ្យឃ្វាលក្របីអី ។

ធានី ៖ ហើយធ្វើអីទៀត?

ស៊ីណាន ៖ ដឹងផង សួរគាត់ ខ្ញុំមិនបានសួរនាំផង ។

ធានី ៖ គាត់ធ្លាប់ប្រាប់ថាលើកទំនប់ លើកអី?

ស៊ីណាន ៖ ទេ! គាត់មិនដែលលើកនេះទេ មិនដែលបានសួរគាត់ ។

ធានី ៖ អត់ដែលបានសួរ?

ស៊ីណាន ៖ នោះឯង បើខ្ញុំមិនដែលបានទៅណាទេ ។

ធានី ៖ ចុះមីងគិតថាការធ្វើអង្ករធ្វើអីនឹងពិបាក?

ស៊ីណាន ៖ ពិបាក វាមានពិបាកប៉ុន្មានទេ ប៉ុនយើងមិនបានទៅឆ្ងាយទេ យើងនៅតែនោះទៅ យើងកិន ទៅធ្វើទៅ ថ្ងៃណាទៅគេឲ្យវាស់អង្ករជិះទូស បើឲ្យប្រជាជនទៅ ។

ធានី ៖ ប្រជាជនទាំងអស់នឹង គាត់បានហូបអង្ករ របៀបថាបានខ្លួនឯង ឬក៏ហូបទាំងសហករណ៍?

ស៊ីណាន ៖ ទេ! នេះ ពីដើមមិញតាមសហករណ៍ ដល់ពេលយូរៗទៅ បានគេបើកចែកតាមគ្រួសារ ។

ធានី ៖ យូរៗបានមានម្ហូប?

ស៊ីណាន ៖ នោះឯង យូរៗបើក មិនមានរាល់ថ្ងៃទេ ។

ធានី ៖ ដឹងថាពេលណាមានអង្ករចែកតាមគ្រួសារ?

ស៊ីណាន ៖ កាលនោះមិននេះផង អត់ចាំទេ ខ្ញុំឆាប់ភ្លេចណាស់នាង គេនិយាយសម័យនោះនិយាយហូរ ខ្ញុំភ្លេចៗ កាលនោះអារម្មណ៍អត់ល្អប្តីបែក អារម្មណ៍ដូចថាវាមិនមូល ។

ធានី ៖ បេះបារម្ភពីគាត់?

ស៊ីណាន ៖ នោះឯង អារម្មណ៍វាអត់មូលទេ ។

ធានី ៖ ចុះពេលឮដឹងថាគ្រួសារមីងស្លាប់ចឹង មីងមានអារម្មណ៍ម៉េចដែរ?

ស៊ីណាន ៖ មានអារម្មណ៍ម៉េច អារម្មណ៍ធ្វើងាប់ ក៏យំ គិតទៅធ្វើបុណ្យប៉ុននោះឯង ។

ធានី ៖ អត់បានទៅយកឲ្យគាត់អី?

ស៊ីណាន ៖ ទេ! ទៅដែរ ប៉ុនគេជីកប់អស់ហើយ យើងដឹងឆ្អឹងណាឆ្អឹងណែ ។ ដល់៨៦ខ្ញុំទៅ ។

ធានី ៖ មីងបានទៅមើលកន្លែង?

ស៊ីណាន ៖ ចា៎! ខ្ញុំទៅមើលកន្លែងផ្ទាល់ គេជីកកប់ ។

ធានី ៖ អ្នកណាគេនាំទៅ?

ស៊ីណាន ៖ ឡានគេនាំទៅ ។

ធានី ៖ ចុះម៉េចបានមីងដឹងថាកន្លែងនឹង?

ស៊ីណាន ៖ បើខ្ញុំធ្លាប់នៅឧត្តរមានជ័យ ។

ធានី ៖ កាលនឹងវត្តអីគេ?

ស៊ីណាន ៖ វត្តឧត្តរមានជ័យនោះឯង ប៉ុនមិនដឹងវត្តអីគេដាក់ឈ្មោះអី មិនដឹងទេ ។

ធានី ៖ ព្រោះកាលនឹងមានតែវត្តមួយ?

ស៊ីណាន ៖ ចា៎! មានតែវត្តមួយប៉ុននោះ ។

ធានី ៖ មាននៅទីរួមខេត្ត?

ស៊ីណាន ៖ នៅកន្លែងរួមខេត្ត នឹងផ្សារនឹងឯង ។

ធានី ៖ បៀតផ្សារ?

ស៊ីណាន ៖ បៀតផ្សារគេនឹង វត្តគេ ។

ធានី ៖ ចឹងដឹងថាវត្តមួយ?

ស៊ីណាន ៖ នោះឯង ដឹងថាវត្តមួយ ។

ធានី ៖ ចុះកាលពេលមីងនៅឧត្តរមានជ័យ ប្រជាជននៅច្រើន ម៉េចបានប្រជាជនគេជម្លៀសចេញ?

ស៊ីណាន ៖ ប្រជាជនគេជម្លៀសចេញទៅដូចតែគ្នា ។

ធានី ៖ ហេតុអីបានគេជម្លៀសប្រជាជន?

ស៊ីណាន ៖ មិនដឹងផង ទៅនៅនោះ គេជម្លៀស ពួកនៅនេះ ម៉ែឪខ្ញុំនៅនេះ គេជម្លៀសទៅនៅស្រុក ។

ធានី ៖ ដល់ពេលមីងអ្នកនៅ?

ស៊ីណាន ៖ ខ្ញុំនៅនោះក៏គេជម្លៀសទៅ ទាំងអស់គ្នាពួកអ្នកស្រុកទៅទាំងអស់គ្នា ។

ធានី ៖ អត់ដឹងថាហេតុអីបានជម្លៀស?

ស៊ីណាន ៖ មិនដឹងទេ ។

ធានី ៖ ហើយជម្លៀសទៅ គេអត់ប្រាប់ថាឲ្យយើងរៀបអីវ៉ាន់អី?

ស៊ីណាន ៖ ទេ! ទៅនៅក៏នៅៗទាល់តែម៉ែក្មេកខ្ញុំទៅស្នើយកមកវិញ ។ ខ្ញុំនៅនោះ ពោះធំគេឲ្យមើលកុមារ មើលកូនង៉ាឲ្យគេ ។

ធានី ៖ ហើយគ្រួសារមីងធ្វើអី?

ស៊ីណាន ៖ គ្រួសារខ្ញុំ គាត់មានកម្លាំង គាត់ដើរទៅស្ទូង ដើរដកទៅ ហើយខ្ញុំនៅមើលកុមារ ។

ធានី ៖ អត់ដឹងម្ដាយក្មេក គាត់មានឆ្មបអី បានអាចហ៊ានធានាមីងបាន?

ស៊ីណាន ៖ ទេ! គ្មានធ្វើអីទេ គាត់អ្នកស្រុកធម្មតា ។

ធានី ៖ អ្នកស្រុកធម្មតា ម៉េចហ៊ានទៅ សូម្បីតែដើរហើរក៏មិនបាន?

ស៊ីណាន ៖ ទេ! សុំបាន ។

ធានី ៖ សុំយ៉ាងម៉េច?

ស៊ីណាន ៖ សុំស្នើកូនយកមកវិញ គេធ្វើខទ្វេសនាមមក យើងយកទៅឲ្យដល់គេអ្នកនោះៗគេមើល ទៅគេឲ្យយើងមក ឲ្យទាំងរទេះមួយ ក្របីម៉ានឹម ដឹកមកទាំងខ្ញុំពោះធំ ដឹកអីវ៉ាន់ ខ្ញុំក៏មកដល់ ក៏ឈឺពោះវិញ ។

ធានី ៖ តាមផ្លូវ ឬមកដល់ផ្ទះហើយ?

ស៊ីណាន ៖ ទេ! កើតតាមឲ្យផ្លូវ កើតនឹងស្រុករំដួលយើង នឹងស្ពានរំដួល បានកូនខ្ញុំដាក់ឈ្មោះរំដួល ។ កូនកើតម៉ោង៩ព្រឹក ក្របីកើតកូនល្ងាចម៉ោង៥ ។

ធានី ៖ ចៃដន្យម្ល៉េះ?

ស៊ីណាន ៖ តែកូននេះ ម៉ែឲ្យខ្ញុំជិះដឹកមកមុនកូនខ្ញុំ ខ្ញុំនេះជិះរទេះបានម៉ាសន្ទុះ បានម៉ែខ្ញុំគាត់យកកង់មួយទៀត ។

ធានី ៖ ចឹងគាត់ទៅជាមួយមីងដែរ?

ស៊ីណាន ៖ ទេ! ម៉ែខ្ញុំគាត់នៅនេះឯង ។

ធានី ៖ ចឹងម៉េចបានគាត់អាច?

ស៊ីណាន ៖ គាត់ឲ្យបងប្អូនដែលធ្វើសេនាជននៅរំដួល ឌុបខ្ញុំមកមុន កូនខ្ញុំមកមុន ក្របីជិះរទេះក្រោយ ។

ធានី ៖ ម៉េចចឹងមីង?

ស៊ីណាន ៖ ចុះក្របីកើតម៉ោង៥ ខ្ញុំកើតម៉ោង៩ ។

ធានី ៖ ចឹងមីងត្រូវមកមុន?

ស៊ីណាន ៖ ចា៎! ខ្ញុំនិងកូនមកមុន ជិះកង់ ។

ធានី ៖ ដឹងក្របីកើតកូន?

ស៊ីណាន ៖ ទេ! មិនដឹងទេ បើខ្ញុំមកដល់ផ្ទះបានគេថាក្របីកើតកូនម៉ោង៥ល្ងាច គេនេះមិក ពួកបងប្អូនខ្ញុំថាក្របីកើតកូនហើយ ក្របីដឹករទេះ ។

ធានី ៖ ម៉ែក្មេកមីង?

ស៊ីណាន ៖ ចា៎!

ធានី ៖ គាត់ឈ្មោះអីគេ?

ស៊ីណាន ៖ យាន ។

ធានី ៖ ស្អីយាន?

ស៊ីណាន ៖ មិនដឹងស្អីយានទេ គាត់នាមត្រកូលគាត់ ។

ធានី ៖ ដូចថាគាត់ជាអ្នកចេះដឹកម៉ារូបដែរ គេគោរពស្រឡាញ់គាត់ដែរ?

ស៊ីណាន ៖ ទេ! មានអីភូមិយើង គេអ្នកស្លុបស្លូតដែរ ។

ធានី ៖ ចឹងបានគាត់អាចពឹងពាក់ឲ្យអ្នកខាងនោះ?

ស៊ីណាន ៖ គាត់មិននេះទេ គាត់ត្រង់ណាក៏គាត់ស្គាល់ដែរ អ្នកធំអ្នកតូចអីគាត់ស្គាល់ ។

ធានី ៖ ប៉ុនគាត់ខ្ជិលអើពើ?

ស៊ីណាន ៖ ចា៎!ដូចសម័យកាលនោះសម័យតាក្រក់នៅនេះ គាត់ស្គាល់តាក្រក់សម័យគាត់សុំតាក្រក់ ។

ធានី ៖ ម៉េចបានគាត់អាចសុំតាក្រក់បាន ព្វថាតាក្រក់នឹងកាចណាស់?

ស៊ីណាន ៖ ដឹងអីគាត់ កាលនោះសម័យតាក្រក់ ។

ធានី ៖ បានសួរគាត់?

ស៊ីណាន ៖ ហ៎! ខ្ញុំមិនបានសួរផង ព្វសួរថាម៉ែក្មេកមកយក ឪក្មេកខ្ញុំមកយក ។

ធានី ៖ ឪក្មេកនឹងគាត់ធ្វើអីគេ?

ស៊ីណាន ៖ អ្នកស្រែសុទ្ធ ។

ធានី ៖ គាត់ឈ្មោះអីគេ?

ស៊ីណាន ៖ ឈ្មោះ ឈាន ។

ធានី ៖ ឪពុកក្មេកមីងអ្នកទៅយកបន្ត?

ស៊ីណាន ៖ ចា៎!

ធានី ៖ ប្រាប់ឲ្យខាងរំដួលនេះ ជួយមីងទៀត ជួយសម្រាល ហើយដឹកមកទៀត?

ស៊ីណាន ៖ ចា៎!

ធានី ៖ ចឹងកាលនឹង ម៉ែក្មេកមីងអ្នកស្នើគាក្រក់ផ្ទាល់ ឬក៏ឪពុកក្មេក?

ស៊ីណាន ៖ ទេ! មិនដឹងអ្នកណាស្នើទេ ប៉ុនឪពុកក្មេកខ្ញុំមិនបានស្នើទេ បើម៉ែក្មេកខ្ញុំស្នើ ។

ធានី ៖ ម៉ែក្មេកអ្នកស្នើ?

ស៊ីណាន ៖ ចា៎!

ធានី ៖ ចឹងមីងស្គាល់គាក្រក់នឹង ធ្លាប់ឃើញមុខគាត់?

ស៊ីណាន ៖ ឃើញតើ ខ្ញុំមកដល់ទាន់ ។

ធានី ៖ គាត់ខស្សព្វាហ៍មកលេងផ្ទះមីងដែរ?

ស៊ីណាន ៖ ទេ! ទៅអង្គការ ដែលទៅហ៊ានមកណា ។

ធានី ៖ រូបរាងគាត់ម៉េចដែរ?

ស៊ីណាន ៖ រូបរាងគាត់ខ្ពស់ៗស្គើង មិនសូវជាធំប៉ុន្មានទេគាត់ ។

ធានី ៖ សំបុរយ៉ាងម៉េចគាត់?

ស៊ីណាន ៖ ខ្មៅស្រអែមគាក្រក់ ឃើញតែគាត់ពាក់អាវ មិនសូវដែលបានឃើញញឹកញាប់ផង ។

ធានី ៖ ចុះក្រៅពីគាក្រក់ មានដែលឃើញអ្នកផ្សេងទៀត?

ស៊ីណាន ៖ មានផ្សេងទៀតនោះឯង ប៉ុនមិនដឹងណាទេ សម័យនោះខ្ញុំម៉ាជនិទាន់គាក្រក់ ។ គេយកគាក្រក់ទៅ បានម៉ាជនិទាន់និរតីចុះមក ។

ធានី ៖ ចឹងបានមីងប្រាប់ថាឈ្មោះ រ៉េមមក?

ស៊ីណាន ៖ ចា៎! នោះឯង ឈ្មោះនោះមក ។

ធានី ៖ តែរ៉េម យ៉ែម ម្តាយរបស់មីងនៅរាប់អានពួកគាត់ទៀតទេ?

ស៊ីណាន ៖ ដែលហ៊ានរាប់អានអី គ្រាន់តែថាពេលទៅគេបើកអង្ករឲ្យ យើងចេះតែទៅៗ ។

ធានី ៖ តែដល់ពេលម៉ាហឹកគាក្រក់នៅបានគាត់ទៅរាប់អាន?

ស៊ីណាន ៖ នោះហើយ មិនមែនទេ ដែលថាបើកអង្ករតាមគ្រួសារនោះ មិនមែនទេ បើកតាមក្រុមទេ បបរ ។

ធានី ៖ ចឹងក្រោយពេលបែកមក មីងនៅស្រុកយើងរហូតដល់វៀតណាមចូលមក ក៏នៅស្រុកយើង?

ស៊ីណាន ៖ ចា៎! នៅស្រុកនេះឯងដែរ មិនបានទៅណាទេ ។

ធានី ៖ មីងឮថាគេខ្មែរក្រហម គេជម្លៀសទៅជម្លៀសឡើងទៀតអត់?

ស៊ីណាន ៖ អត់ទេ ។

ធានី ៖ ហើយម្ដាយមីងនៅជុំគ្នាបងប្អូន?

ស៊ីណាន ៖ នៅជុំគ្នាបងប្អូនខ្ញុំ ។

ធានី ៖ មានបាត់បងប្អូន?

ស៊ីណាន ៖ មិនមានទេ មានបងតែមួយគេ មីងពោះធំ ។

ធានី ៖ ចឹងមីងខ្ញុំដូចជាអស់សំនួរចង់សួរមីងៗមានអីចង់សួរខ្ញុំ?

ស៊ីណាន ៖ ទេ! មិនមានចង់ចិត្តសួរ សួរខ្ញុំមិនច្បាស់លាស់ទេ ថាដូចខ្ញុំជម្រាបចេះឯង បែកប្ដីទៅក៏អារម្មណ៍មិនល្អដូចសព្វថ្ងៃក៏ដូចគ្នា ។ ខ្ញុំរឿងអីខ្ញុំភ្លេចអស់ហើយ មើលប្អូនថ្លៃខ្ញុំបែកគ្នាកាលសម័យប៉ុលពត ។ វាទើបមករកម្សិលម៉ោថ្ងៃមិញ មិនដឹងថាវានោះទៅពីអន្លង់ណា គេអ្នកផ្សេងគេចាំបាន ខ្ញុំភ្លេចហើយ ដឹងថារឿងអីបានវាបែក ប្ដីប្រពន្ធឈ្លោះគ្នាចេះចុះខ្ញុំភ្លេច ។

ធានី ៖ គាត់មកពីណាវិញ?

ស៊ីណាន ៖ មកទៅបែកគ្នាទៅ គេក៏បានប្ដីស៊ីម៉ាក់ ។ មិនមែនសម័យអាពតនេះទេ សម័យយួនចូលហើយនេះឯង ប្អូនខ្ញុំបង្កើតវាបាននាង ។ ដល់បានទៅឈ្លោះប្រកែកគ្នាទៅ ក៏គេរត់ទៅ ខ្ញុំនឹងគេមកគេនិយាយដំណាលរហូត គេអ្នកដំណើរ ខ្ញុំនោះភ្លេចអស់ៗមិនដឹងមូលហេតុអីបានជាវាឈ្លោះគ្នា លែងគ្នា មូលហេតុអីមិនដឹងទេ ភ្លេចអស់ហើយ ។

ធានី ៖ ចា៎! ចឹងអរគុណមីងច្រើន ។

ស៊ីណាន ៖ ចា៎!

«ចប់»